ISSN 1810-6358

វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា

**Cambodia Development Resource Institute**

# របាយការណ៍ថ្មីៗស្តីពីសេដ្ឋកិច្ចកម្ពុជា

# Flash Report on the Cambodian Economy

តុលា ២០០៥ / October 2005

កញ្ញា អ៊ូច ច័ន្ទតារានី / **Ms. Ouch Chandarany**

លោកស្រី ប៉ុន ដូរីណា / **Ms. Pon Dorina**

លោក ហ៊ីង វុត្ថា / **Mr. Hing Vutha**

លោក ភីម រុនស៊ីណារិទ្ធិ / **Mr. Phim Runsinarith**

បកប្រែដោយៈ យូ សិទ្ធីរិទ្ធ

ភ្នំពេញ កម្ពុជា

**Phnom Penh, Cambodia**

**TO SUBSCRIBE, PLEASE CONTACT:**

*Office Address:* #56, Street 315, Tuol Kork, Phnom Penh, Cambodia, *Postal Address:* CDRI, PO Box 622 Phnom Penh, Cambodia
*Tel:* (855-23) 881-384/881-701/881-916/883-603 *Tel/fax:* (855-23) 880-734 *E-mail:* pubs@cdri.forum.org.kh *Website:* http://www.cdri.org.kh

# សកម្មភាពសេដ្ឋកិច្ចសំខាន់ៗរបស់កម្ពុជា

# Main Economic Activities of Cambodia

នៅត្រីមាសទី២ ២០០៥ វិនិយោគឯកជនក្នុងវិស័យសេវាកម្មដែល CDC បានអនុម័តមានចំនួន ៣០លានដុល្លារ ដែលត្រូវបានយកទៅបណ្តាក់ទុនក្នុងក្រុមហ៊ុនសាងសង់ ដោយជនកម្ពុជា ។ វិនិយោគក្នុងវិស័យនេះ ថយចុះប្រហែល ៣៣%ធៀបនឹងត្រីមាសមុន និង ថយចុះ ៦០,៥%ធៀបនឹងត្រីមាសដូចគ្នាឆ្នាំមុន ។

Private investment in the services sector approved by the CDC in the second quarter of 2005 amounted to $30 million, which was invested in construction companies by Cambodians. Investment in the sector declined by about 33 percent compared to the preceding quarter, and by 60.5 percent compared to the same quarter last year.

**Private Investment in Services Sector Approved by CDC** (US$ million)




*Note: Data for May–June 2005 exclude expansion project approvals.*
Source: Council for the Development of Cambodia

នៅខែកក្កដា ភ្ញៀវបរទេសចូលតាមជើងហោះហើរអន្តរជាតិ កើន ១៦,២% (ធៀបនឹងខែមិថុនា) ដល់ ៣៦.៧៤២នាក់ សំរាប់អាកាសយានដ្ឋានភ្នំពេញ និងកើន ៥៤,៧% ដល់ ៣១.៨៧៨នាក់សំរាប់អាកាសយានដ្ឋានសៀមរាប ។ បើធៀបនឹងខែដូចគ្នាឆ្នាំមុន ភ្ញៀវចូលតាមច្រកភ្នំពេញកើន ៣៥% និងតាមច្រកសៀមរាបកើន ១១,៤% ។

In July, foreign visitor arrivals by international flights at both Phnom Penh and Siem Reap international airports increased compared to June. Arrivals at Phnom Penh airport rose by 16.2 percent to 36,742 persons, and arrivals at Siem Reap by 54.7 percent to 31,878 persons. Compared to the same month last year, visitor arrivals at Phnom Penh airport rose by 35 percent and at Siem Reap airport fell by 11.4 percent.

**Foreign Visitor Arrivals by International Flights**
(thousand persons)




*Note: Latest data available are for July 2005.*
Source: Ministry of Tourism

គំរោងសាងសង់អនុម័តដោយ មន្ទីរសុរិយោដីនិងភូមិសាស្ត្រក្រុងភ្នំពេញ មានតំលៃសរុប ៣២,៦លានដុល្លារនៅខែកក្កដា ធៀបនឹង៥៤,៤លានដុល្លារនៅខែមិថុនា ។ ផ្ទះល្វែង និងសំណង់ឯទៀត ថយចុះពី ៣៧,១លានដុល្លារ ដល់១៦,១លានដុល្លារ និងពី ១៥,៣លានដុល្លារ ដល់ ៤លានដុល្លារ រៀងគ្នា ចំណែកឯ ភូមិគ្រឹះកើនពី ២,១លានដុល្លារ ដល់ ១២,៥លានដុល្លារ ។ តំលៃសរុបនៃគំរោងសាងសង់ដែលបានអនុម័តនេះ មានកំរិតប្រហែល ៣៦% ខ្ពស់ជាងកាលពីខែកក្កដា ២០០៤ ។

Construction projects approved by the Department of Cadastre and Geography of the municipality of Phnom Penh were worth $32.6 million in July, declining from $54.4 million in June. Flats and other construction declined to $16.1 million from $37.1 million and to $4 million from $15.3 million respectively, while villa and house construction rose to $12.5 million from $2.1 million. The total value of construction project approvals was about 36 percent higher than in July 2004.

**Value of Construction Project Approvals in Phnom Penh** (US$ million)




*Note: Latest data available are for July 2005.*
Source: Phnom Penh Department of Cadastre and Geography

# អត្រាការប្រាក់ និង ថ្លៃទំនិញ

# Price and Interest Rate Developments

នៅខែកញ្ញា ២០០៥ ថ្លៃទីផ្សារនៃសាំង និងម៉ាស៊ូតនៅភ្នំពេញ កើនលឿនជាងកាលពីខែមុន។ ថ្លៃសាំងជាមធ្យម កើន ៦,៦% ដល់ ៣.៧២០៛/លីត្រ នៅខែកញ្ញា ធៀបនឹងកំណើន ៤,៣%នៅខែសីហា ។ ក្នុងពេលដដែល ថ្លៃម៉ាស៊ូតជាមធ្យម កើន ៤,៣% ដល់ ២.៩១៨រៀល/លីត្រ ធៀបនឹងកំណើន ៣,៣%នៅខែមុន ។

The market price of gasoline and diesel in Phnom Penh in September 2005 rose faster than in the preceding month. The average price of gasoline surged by 6.6 percent (to 3,720 riels/litre) in September, compared to a 4.3 percent increase in August. In the meantime, the average price of diesel rose by 4.3 percent (to 2,918 riels/litre), compared to a 3.3 percent rise the previous month.

**Prices of Gasoline and Diesel Oil in Phnom Penh**




Sources: CDRI and National Institute of Statistics

នៅខែសីហា ថ្លៃទំនិញប្រើប្រាស់នៅភ្នំពេញបន្តកើនឡើងតាមអត្រាប្រចាំឆ្នាំ ៤,៥% ធៀបនឹងអត្រាកំនើន៤,១%នៅខែកក្កដា។ សន្ទស្សន៍ថ្លៃម្ហូបអាហារមានអត្រាកំណើនប្រចាំឆ្នាំ ៦% ធៀបនឹង ៥,២%កាលពីខែមុន ចំណែកឯថ្លៃដឹកជញ្ជូនកើន ១១% គឺទាបជាងកាលពីខែកក្កដា ដែលមានអត្រាកំនើន ១១,៩% ។

Consumer prices in Phnom Penh continued to rise in August, rising 4.5 percent over the previous 12 months, compared to an annual growth rate of 4.1 percent in July. The index of food prices increased by 6 percent annually from 5.2 percent, while that of transportation rose 11 percent—less than in July, when it increased 11.9 percent.

**Consumer Price Index**

(July–December 2000=100)




*Note: Latest data available are for August 2005.*

Source: National Institute of Statistics

យោងតាមអង្កេតប្រចាំត្រីមាសលើពលករងាយរងគ្រោះនៅភ្នំពេញ នៅខែសីហា ចំណូលប្រចាំថ្ងៃពិតរបស់កម្មករសំណង់គ្មានជំនាញ និងអ្នករត់ម៉ូតូឌុបបានធ្លាក់ចុះ ២៤% និង ១៤% ដល់ ៦.១៤០រៀល និង ៩.៥២០រៀល រៀងគ្នា ចំនែកឯចំនួលរបស់អ្នកធាក់ស៊ីក្លូកើនឡើងបន្តិច (៣%) បើធៀបនឹងខែឧសភា ។ ប៉ុន្តែធៀបនឹងខែសីហាឆ្នាំមុន ចំនូលប្រចាំថ្ងៃពិតរបស់ពលករទាំងបីក្រុមនេះ បានកើនឡើងទាំងអស់គ្នា ។

According to the quarterly survey of vulnerable workers in Phnom Penh conducted by CDRI, real daily earnings of unskilled construction workers and motorcycle taxi drivers declined in August, compared to May, while earnings of cyclo drivers increased marginally. In August, unskilled construction workers earned, on average, about 6,140 riels per day, 24 percent less than in May. Motorcycle taxi drivers obtained 9,520 riels per day, a 14 percent decrease. Meanwhile, cyclo drivers could earn about 3 percent more than in the preceding quarter. Compared to August last year, real daily earnings of these three vulnerable groups all increased.

**Real Daily Average Earnings of Vulnerable Workers in Phnom Penh**

(at November 2000 prices)




Source: CDRI and Ministry of Economy and Finance

# ស្ថានភាពអត្រាប្តូរប្រាក់និងរូបិយវត្ថុ
# Exchange Rate and Monetary Developments

នៅខែកញ្ញា ប្រាក់រៀលបានចុះថ្លៃទល់នឹងដុល្លារUS ដោយមួយដុល្លារប្តូរបានជាមធ្យមនៅទីផ្សារ ៤.២០៨,៤រៀល ធៀបនឹង ៤.១៨២រៀលនៅខែមុន និង ៤.០៨០រៀលនៅខែកញ្ញាឆ្នាំមុន ។

The riel depreciated against the US dollar in September, trading at an average market rate of 4,208.4 riels/dollar, from 4,182 in the preceding month and 4,080 in the same month last year.

**Riels per US Dollar**




Sources: National Bank of Cambodia and CDRI

នៅខែកញ្ញា ប្រាក់រៀលបន្តចុះថ្លៃទល់នឹងប្រាក់បាតថៃ និង ដុងវៀតណាម ដោយប្តូរបានជាមធ្យម ១០២,៧រៀល/បាត (រឺចុះថ្លៃ ១%ធៀបនឹងខែសីហា) និង ២៦,៤រៀល/១០០ដុង (រឺចុះថ្លៃ ០,៥%ធៀបនឹងខែមុន) ។ ធៀបនឹងខែកញ្ញាឆ្នាំមុន ប្រាក់រៀលចុះថ្លៃអស់ ៤%ទល់នឹងប្រាក់បាត និង ៥,៥%ទល់នឹងប្រាក់ដុងវៀតណាម ។

The riel continued to depreciate against the Thai baht and the Vietnamese dong in September. The riel/baht exchange rate during September averaged 102.7, a depreciation of about 1 percent from August. Against the dong, the riel depreciated by 0.5 percent to 26.4 riels per 100 dong. Compared to September last year, the riel has fallen against the baht and the dong about 4 percent and 5.5 percent, respectively.

**Riels per Thai Baht and 100 Vietnamese Dong**




Source: CDRI

ក្រោយកើនបានបន្តិចនៅខែមិថុនា រូបិយវត្ថុទូទៅកើនបាន ៣,៣%នៅខែកក្កដា ដល់ ៤.៧៨០,៨ពាន់លានរៀល ។ ប្រាក់បញ្ញើជារូបិយវត្ថុបរទេសកើន ២,២% ដល់ ៨២០លានដុល្លារ (៣.៤៤៤,៤ពាន់លានរៀល) ។ ប្រាក់រៀលនៅក្រៅធនាគារកើន ១,១% ដល់ ១.១៨០ពាន់លានរៀល រីឯប្រាក់បញ្ញើជារៀលនៅធនាគារថយចុះ ៦% មកត្រឹម ១៥៦,៤ពាន់លានរៀល ។ ធៀបនឹងខែកក្កដាឆ្នាំមុន រូបិយវត្ថុទូទៅកើនបាន ២០,៤% ។

After a slight decrease in June, total liquidity grew by 3.3 percent, to 4,780.8 billion riels, in July. Foreign currency deposits rose by 2.2 percent to $820 million (3,444.4 billion riels). Riels outside banks increased by 1.1 percent to 1,180 billion, while riels in bank deposits declined by about 6 percent to 156.4 billion riels. Compared to July last year, total liquidity was up by 20.4 percent.

**Liquidity of the Banking System**
(billion riels)




*Note: Latest data available are for July 2005.*
Source: National Bank of Cambodia

# ពាណិជ្ជកម្មក្រៅប្រទេស

# External Trade

ពីខែមិថុនា ដល់ កក្កដា ការនាំចេញសំលៀកបំពាក់ និងអង្ករ កើនប្រហែល ២៤% ដល់ ២៤៨,៨លានដុល្លារ និង ៣៩,៧% ដល់ ០,៤លានដុល្លារ រៀងគ្នា ។ ចំណែកឯការនាំចេញកៅស៊ូ និងត្រី ថយចុះប្រហែល ៤% ដល់ ៣,១លានដុល្លារ និង ៤,៥% ដល់ ០,២លានដុល្លារ រៀងគ្នា ។ ការនាំចេញសរុបរបស់កម្ពុជា កើន ២២,៣% ដល់ ២៥៥,១លានដុល្លារ ។ ធៀបនឹងខែកក្កដាឆ្នាំមុន ការនាំចេញសរុបកើនឡើង ១២,៧% ។

Between June and July, garment and rice exports rose respectively by about 24 percent, to $248.8 million, and by 39.7 percent to $0.4 million, while rubber and fish exports declined by around 4 percent, to $3.1 million, and by 4.5 percent, to $0.2 million. Accordingly, Cambodia's total exports increased by 22.3 percent to $255.1 million. They also increased by 12.7 percent from July last year.

**Cambodia's Main Exports**
(US$ million)




*Note Latest data available are for July 2005.*
Source: Customs and Excise Department

នៅខែកក្កដា ការនាំចូលបារី និងស៊ីម៉ងត៍ បានថយចុះ ឯការនាំចូលដែកបានកើនឡើង ។ ការនាំចូលបារីមានចំនួន ២៦,៩ពាន់លានរៀលនៅខែកក្កដា រឺ ៩%តិចជាងពីខែមិថុនា ឯការនាំចូលស៊ីម៉ង់ត៍មាន ១៨,១ពាន់លានរៀល រឺថយចុះ ៤,៤% ។ ផ្ទុយទៅវិញ ការនាំចូលដែក កើនដល់ ១១,៨ពាន់លានរៀល ពីក៏រិត ៥,១ពាន់លានរៀល ។

Imports of cigarettes and cement decreased in July, while imports of steel increased. Cigarette imports amounted to 26.9 billion riels in July, 9 percent less than in June, and cement imports reached 18.1 billion riels, a decrease of 4.4 percent. However, steel imports rose to 11.8 billion riels from 5.1 billion riels.

**Imports of Cigarette and Construction Materials**
(billion riels)




*Note: Latest data available are for July 2005.*
*(Excluding public sector imports.)*
Source: Customs and Excise Department

នៅខែកក្កដា ការនាំចូលម៉ាស៊ូតកើន ៥៤,៥% ដល់ ៤១,២ពាន់លានរៀល ឯការនាំចូលសាំង កើន ២,២% ដល់ ១៣,៤ពាន់លានរៀល ។ ប៉ុន្តែបើធៀបនឹងខែកក្កដា ២00៤ ការនាំចូលម៉ាស៊ូតថយចុះ ៤,៧% រីឯការនាំចូលសាំងកើនជិតមួយជាបី ។

In July, diesel imports rose by 54.5 percent to 41.2 billion riels, while gasoline imports increased by 2.2 percent to 13.4 billion riels. Compared to July 2004, however, diesel imports declined by 4.7 percent, while gasoline imports nearly tripled.

**Imports of Petroleum Products**
(billion riels)




*Note: Latest data available are for July 2005.*
*(Excluding public sector imports.)*
Source: Customs and Excise Department

# ប្រភពនិងការប្រើប្រាស់ជំនួយបរទេស

# Sources and Uses of Foreign Assistance

នៅឆ្នាំ២០០៥ មានការបែងចែកមូលនិធិឃុំ-សង្កាត់ ៧,៨ពាន់លានរៀល ទៅឱ្យខេត្តកំពង់ចាម ដែលជាចំនួនច្រើនជាងគេ ក្នុងចំណោមខេត្ត-ក្រុង ទាំង ២៤ ។ ក្នុងទឹកប្រាក់នេះ ៦៨% (៥,៣ពាន់លានរៀល) ត្រូវបាន បែងចែកសំរាប់ការអភិវឌ្ឍន៍ ហើយនៅសល់ប៉ុន្មានគឺសំរាប់ខាងរដ្ឋបាល ។ ធៀបនឹងឆ្នាំ២០០៤ មូលនិធិ ឃុំ-សង្កាត់ដែលបែងចែកឱ្យខេត្តកំពង់ចាម កើនឡើង ១២,៧% ។

In 2005, the commune/sangkat fund allocated 7.8 billion riels to Kompong Cham province—the biggest recipient among 24 provinces and cities. Of this, allocations for development accounted for 68 percent (5.3 billion riels). The remainder was allocated for administration. Compared to 2004, the commune/sangkat fund allocation for Kompong Cham increased by 12.7 percent.

**2005 Commune/Sangkat Fund Allocation to Kompong Cham Province**




Source: Seila Task Force (January 2005), Annual Work Plan and Budget 2005

ខេត្តកណ្ដាលទទួលបានមូលនិធិឃុំ-សង្កាត់ធំជាងគេលំដាប់ទី២ គឺប្រហែល ៦ពាន់លានរៀល នៅឆ្នាំ២០០៥ ។ ក្នុងនេះទឹកប្រាក់បែងចែកសំរាប់ការ អភិវឌ្ឍន៍មាន ៤,១ពាន់លានរៀល និងសំរាប់ខាងរដ្ឋបាលមានប្រហែល ១,៩ពាន់លានរៀល ។ មូលនិធិឃុំ-សង្កាត់ដែលបែងចែកឱ្យខេត្តកណ្ដាល នៅឆ្នាំ២០០៥ មានទំហំ ១៣,៥% ច្រើនជាងឆ្នាំ២០០៤ ។

Kandal received the second largest amount from the commune/sangkat fund, about 6 billion riels, in 2005. Allocation for development was about 4.1 billion riels, and for administration around 1.9 billion riels. The commune/sangkat fund allocation to Kandal in 2005 was 13.5 percent more than in 2004.

**2005 Commune/Sangkat Fund Allocation to Kandal Province**




Source: Seila Task Force (January 2005), Annual Work Plan and Budget 2005

មូលនិធិឃុំ-សង្កាត់សរុបប្រហែល ៥ពាន់លានរៀលត្រូវបានបែងចែកទៅឱ្យ ខេត្តព្រៃវែង ដែលក្នុងនេះ ៣,៤ពាន់លានរៀលជាមូលនិធិសំរាប់អភិវឌ្ឍន៍ និង១,៦ពាន់លានរៀលជាមូលនិធិសំរាប់រដ្ឋបាល ។ ធៀបនឹងឆ្នាំមុន មូលនិធិ ឃុំ-សង្កាត់ដែលបែងចែកទៅឱ្យខេត្តព្រៃវែងកើនឡើង ១៣% ។

A total of about 5 billion riels from the commune/sangkat fund was allocated in 2005 to Prey Veng province, of which 3.4 billion riels was development funds and 1.6 billion riels was administration funds. Compared to last year, the commune/sangkat fund allocation for Prey Veng rose by 13 percent.

**2005 Commune/Sangkat Fund Allocation to Prey Veng Province**




Source: Seila Task Force (January 2005), Annual Work Plan and Budget 2005

# ការអនុវត្តន៍ថវិកាជាតិ
# National Budget Operations

នៅត្រីមាសទី២ អតិរេកថវិកាចរន្តរបស់កម្ពុជា ចុះទាបជាងត្រីមាសទី១ ប៉ុន្តែកើនឡើងធៀបនឹងត្រីមាសទី២ ២០០៤ ។ វាមានទំហំ ២៤៥,៣ពាន់លានដុល្លារ នៅត្រីមាសទី២ ២០០៥ ធៀបនឹង ២៧៣,៥ពាន់លានដុល្លារនៅត្រីមាសទី១ និង ១៨៨,១ពាន់លានដុល្លារនៅត្រីមាសទី២ ឆ្នាំមុន ។

In the second quarter, Cambodia's current budget surplus declined from the first quarter, but increased from the same quarter of 2004. It was recorded at 245.3 billion riels in second quarter 2005, compared to 273.5 billion riels in the first quarter and 188.1 billion in the second quarter last year.

**Current Budget Operations**
(billion riels)




*Note: Provisional for 2004 and Q1 &Q2-05.*
Source: Ministry of Economy and Finance

នៅត្រីមាសទី២ ឆ្នាំ២០០៥ ចំនូលថវិកាចរន្តមាន ៦១១,៥ពាន់លានរៀល វី ១០,៩%ច្រើនជាងនៅត្រីមាសមុន តែធៀបនឹងត្រីមាសទី២ ២០០៤ វាកើន ២៨,៦% ។ ក្នុងរយៈ១២ខែ ពន្ធក្នុងស្រុកកើន ៦៨% ដល់ ១៤៧,៦ពាន់លានរៀល, ពន្ធនាំចេញ-នាំចូលកើន ២២% ដល់ ៣១៨,៤ពាន់លានរៀល និង ចំនូលមិនមែនពន្ធកើន ១៤,៥% ដល់ ១៤៥,៥ពាន់លានរៀល ។

In second quarter 2005, current budget revenue was 611.5 billion riels, 10.9 percent more than in the preceding quarter. Compared to the second quarter last year, it rose by 28.6 percent. In the 12 months, domestic tax rose by 68 percent to 147.6 billion riels, import and export tax increased by 22 percent to 318.4 billion riels, and non-tax revenue grew by 14.5 percent to 145.5 billion riels.

**Current Budget Revenue**
(billion riels)




*Note: Provisional for 2004 and Q1 &Q2 2005.*
Source: Ministry of Economy and Finance

នៅត្រីមាសទី២ ចំនាយថវិកាចរន្តមានទំហំ ៣២%ច្រើនជាងត្រីមាសទី១។ ដូចគ្នាដែរ បើធៀបនឹងត្រីមាសទី២ ២០០៤ ចំនាយចរន្តកើន ២៧,៤% ដោយសារជាសំខាន់មកពី កំនើនចំនាយរដ្ឋបាលទូទៅ និងកំនើនចំនាយរដ្ឋបាលសេដ្ឋកិច្ច ។

In the second quarter, current budget expenditure was 32 percent more than in the first quarter. Similarly, compared to the second quarter of 2004, current expenditure was up 27.4 percent. An increase in spending on general and economic administration was the main factor in the increase in current expenditure during this period.

**Current Budget Expenditure**
(billion riels)




*Note: Provisional for 2004 and Q1 &Q2 2005.*
Source: Ministry of Economy and Finance

# សកម្មភាពសេដ្ឋកិច្ចនៃបណ្តាប្រទេសជាដៃគូរបស់កម្ពុជា

# Economic Activity of Selected Economic Partners of Cambodia

នៅត្រីមាសទី២ ២០០៥ ផសសUS ពិត កើនតាមអត្រាប្រចាំឆ្នាំ ៣,៣% គឺថយសន្ទុះពីកំនើន ៣,៨%នៅត្រីមាសទី១។ រឿងនេះឆ្លុះបញ្ចាំងជាសំខាន់ពីការថយចុះវិនិយោគលើស្តុកទំនិញឯកជន ។ ផសស ពិតនៅតំបន់អឺរ៉ូ នៅត្រីមាសទី២ ២០០៥ មានកំរិត ១,២%ខ្ពស់ជាងត្រីមាសដូចគ្នា ឆ្នាំមុន និង ០,៣%ខ្ពស់ជាងត្រីមាសមុន ។ ផសស ជប៉ុន មានអត្រាកំនើនប្រចាំឆ្នាំ ១,៤%នៅត្រីមាសទី២ ២០០៥ ធៀបនឹងកំនើន ១,៣% នៅត្រីមាសទី១ ។

US real GDP in the second quarter 2005 grew at an annual rate of 3.3 percent, a deceleration from 3.8 percent in the first quarter. This primarily reflected a downturn in private inventory investment. Real GDP of the euro zone in second quarter 2005 was 1.2 percent higher than in the same quarter of the previous year and 0.3 percent higher than in the previous quarter. Japanese GDP grew by 1.4 percent in the year to second quarter 2005, an increase from 1.3 percent annual growth to first quarter 2005.

**GDP Growth Rates by Quarter**

(Percent change over a year earlier)




Sources: BEA, Eurostat and *Economist*

នៅត្រីមាសទី២ ២០០៥ ផសស ចិន មានអត្រាកំនើនប្រចាំឆ្នាំ ៩,៥% គឺដូចគ្នានឹងត្រីមាសមុន ដែលជំរុញជាសំខាន់ដោយសារ ផលិតកម្មឧស្សាហកម្ម, វិនិយោគ និងចំនាយប្រើប្រាស់តាមគ្រួសារ ។ ដូចគ្នាដែរ ផសស ពិត កូរ៉េខាងត្បូង មានអត្រាកំនើន ៣,៣%នៅត្រីមាសទី២ ធៀបនឹង ២,៧%នៅត្រីមាសទី១ (ដែលជំរុញដោយឧស្សាហកម្មគ្រប់ផ្នែក ជាពិសេសខាងសាងសង់) ។ ឯនៅហុងកុង វាមានកំនើន ៦,៨%នៅត្រីមាសទី២ ២០០៥ នេះ ។

China's GDP in the second quarter 2005 grew at the same annual rate as in the previous quarter, by 9.5 percent. Growth was driven primarily by industrial production, exports, investment and domestic consumption. The real GDP of South Korea grew 3.3 percent in the year to second quarter 2005, compared with 2.7 percent in the year to first quarter 2005. Positive growth in all industries, especially construction, contributed to the increase. The real GDP of Hong Kong grew 6.8 percent in the year to second quarter 2005.

**GDP Growth Rates by Quarter**

(Percent change over a year earlier)




Sources: National statistics departments of each country

ផសស ពិត នៅម៉ាឡេស៊ី មានអត្រាកំនើនប្រចាំឆ្នាំ ៤,១%នៅត្រីមាសទី២ ២០០៥ ធៀបនឹង ៥,៧%នៅត្រីមាសមុន ។ នៅថៃ វាមានកំរិត ៤,៤%នៅត្រីមាសទី២ និង៣,៤%នៅត្រីមាសទី១ ក្នុងនេះផ្នែកកម្មន្តសាល, សាងសង់ ដឹកជញ្ជូន និងទូរគមនាគមន៍ មានកំនើនបង្គួរ រីឯកសិកម្មបានរួមតូច។ នៅសិង្ហបុរី វាមានកំរិត ៥,២%នៅត្រីមាសទី២ និង ២,៥%នៅត្រីមាសទី១។

The real GDP of Malaysia in the year to second quarter 2005 grew by 4.1 percent, compared to 5.7 percent to the previous quarter. The GDP of Thailand in the year grew 4.4 percent, compared to 3.4 percent in the year to the previous quarter. Manufacturing, construction, transport and communication registered moderate growth, while agriculture shrunk. Singapore's GDP grew 5.2 percent in the year to second quarter 2005, compared with 2.5 percent in the year to the previous quarter.

**GDP Growth Rates by Quarter**

(Percent change over a year earlier)




Sources: Countries' national statistics offices and national banks

# ស្ថានភាពអតិផរណានៃបណ្តាប្រទេសជាដៃគូរបស់កម្ពុជា

# Inflation Rates in Selected Economic Partners of Cambodia

នៅខែកក្កដា អតិផរណានៅតំបន់អឺរ៉ូ ឡើងដល់ ២,២% ដោយសារជាសំខាន់មកពីការស្ទុះឡើងនាពេលថ្មីៗនៃថ្លៃប្រេងគិតជាអឺរ៉ូ ។ កំនើននេះត្រូវបានកាត់បន្ថយមួយចំនែកវិញដោយសារអត្រាឡើងថ្លៃទំនិញប្រើប្រាស់ភាគច្រើនថយចុះ ជាពិសេស ម្ហូបអាហារគ្មានកែច្នៃ និងទំនិញឧស្សាហកម្មមិនមែនថាមពល ។ ក្នុងរយៈពេលដដែល អតិផរណាថ្លៃទំនិញប្រើប្រាស់កើនដល់ ៣,២%នៅសហរដ្ឋអាមេរិក និង -០,៣%នៅជប៉ុន ។

Euro area inflation edged up to 2.2 percent in July. This increase largely reflected the recent surge in euro-denominated oil prices, which has put strong upward pressure on energy prices. This was only partly counterbalanced by declining price growth rates in most other CPI components, in particular unprocessed food and non-energy industrial goods. During the same period, consumer inflation rose to 3.2 percent in the US and to -0.3 percent in Japan.

### Inflation Rates in the US, Europe and Japan

(percentage prices change over the previous year)




*Note: The latest data available are for July 2005.*
Sources: IMF and the *Economist* (10–16 September 2005)

នៅហុងកុង អត្រាអតិផរណាប្រចាំឆ្នាំបន្តស្ទុះឡើងក្នុង ៣ត្រីមាសជាប់ៗគ្នា ឡើងដល់ ១,៣%នៅខែកក្កដា ដែលបណ្តាលជាសំខាន់មកពីកំនើនជាថ្មីទៀតនៃថ្លៃឈ្នួលផ្ទះឯកជន និងកំនើនយ៉ាងច្រើននៃថ្លៃសំលៀកបំពាក់ និងស្បែកជើង ។ ក្នុងរយៈពេលដដែល អត្រាអតិផរណាប្រចាំឆ្នាំនៃថ្លៃទំនិញប្រើប្រាស់ បានថយចុះមកត្រឹម ២,៥%នៅចិន ប៉ុន្តែ ឡើងដល់ ១,៨%នៅកូរ៉េខាងត្បូង ។

Hong Kong year-on-year inflation continued to accelerate for the third consecutive month, reaching 1.3 percent in July. This was mainly attributable to a renewed increase in private housing rents and a larger increase in the prices of clothing and footwear. During the same period, the annual rate of consumer inflation moderated to 2.5 percent in China and climbed to 1.8 percent in South Korea.

### Inflation Rates in China, Hong Kong and S. Korea

(percentage prices change over the previous year)




*Note: The latest data available are for July 2005.*
Sources: IMF and the *Economist* (10–16 September 2005)

នៅខែកក្កដា ថ្លៃទំនិញប្រើប្រាស់នៅសិង្ហបុរី មានកំរិត ០,១% ខ្ពស់ជាងកាលពីមួយឆ្នាំមុន ។ យោងតាម នាយកដ្ឋានស្ថិតិសិង្ហបុរី រឿងនេះបណ្តាលជាសំខាន់មកពីកំនើនថ្លៃម្ហូបអាហារ ផ្ទះសំបែង ការថែទាំសុខភាព និងលំហែកំសាន្ត ។ ក្នុងរយៈពេលដដែល សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់កើន ៣%នៅម៉ាឡេស៊ី និង ៥,៣%នៅថៃ ។

Singapore's consumer prices in July were 0.1 percent higher than a year earlier. According to the Department of Statistics of Singapore, this largely reflected higher costs of food, housing, health care and recreation. In the same period, the consumer price index rose by 3 percent in Malaysia and 5.3 percent in Thailand.

### Inflation Rates in Selected ASEAN Countries

(percentage prices change over the previous year)




*Note: The latest data available are for July 2005.*
Sources: IMF and the *Economist* (10–16 September 2005)

# អត្រាប្តូរប្រាក់លើទីផ្សារអន្តរជាតិ

# Exchange Rates in World Markets

នៅខែកញ្ញា ២០០៥ ដុល្លារUS ឡើងថ្លៃបន្តិចទល់នឹងប្រាក់អឺរ៉ូ និង យ៉េនជប៉ុន គឺ ១ដុល្លារប្តូរបាន ០,៨២អឺរ៉ូ រឺ ១១០,៩៥យ៉េន ។ ការឡើងថ្លៃនេះអាចបណ្តាលមកពី ការថយចុះខ្លះនៃការបារម្ភក្នុងទីផ្សារអំពីអតុល្យភាពឥតឈប់ឈរនៃជញ្ជីងពាណិជ្ជកម្ម ក្រោយការផ្សព្វផ្សាយទិន្នន័យពីលំហូរទុនវិនិយោគជាភាគហ៊ុនយ៉ាងច្រើនចូលមក US សំរាប់ខែមិថុនា។ ប្រាក់ដុល្លារក៏មានជំនួយទ្រទ្រង់ពីគំលាតអត្រាការប្រាក់ រវាង US និងតំបន់អឺរ៉ូ ដែរ ។

In September 2005, the US dollar gained strength slightly against the euro and the Japanese yen, trading at 0.82 against the euro and 110.95 against the yen. This strengthening may reflect some easing of market concerns about the persistence of trade imbalances following the release of US portfolio investment flow data for June, which showed that the US had been attracting considerable inflows. The dollar also received some support from the widening interest rate differentials between the US and the euro area.

## Euro and Japanese Yen against US Dollar




*Note: Data are up to 29 September 2005.*
Source: Federal Reserve Bank of New York

នៅខែកញ្ញា ប្រាក់វ៉ុនកូរ៉េខាងត្បូង ប្តូរបាន ១.០២៨,៥៩វ៉ុន/ដុល្លារUS រឺចុះថ្លៃ ០,៧%ធៀបនឹងខែមុន។ ប្រាក់វ៉ុនក៏ទទួលសំពាធពីតំរូវការប្រាក់ដុល្លារពីសំណាក់អ្នកលក់ភាគហ៊ុនបរទេស ។ ក្នុងខែនេះដែរ ១ដុល្លារUS ប្តូរបាន ៧,៧៦ដុល្លារហុងកុង ហើយReuters អះអាងថា ដុល្លារហុងកុងត្រូវបានទ្រទ្រង់ដោយការប្រមើលថា នឹងមានលំហូរទុនច្រើនទៀតចូលមកហុងកុង ។

In September, the South Korean won weakened against the US dollar, trading at 1028.59, a 0.7 percent depreciation from a month earlier. The dollar's advance against the yen raised expectations for additional gains in relation to the won. The won was also weighed down by demand for dollars by foreign equity sellers. During the same period, the Hong Kong dollar traded at 7.76 against its US counterpart. According to Reuters, the Hong Kong dollar was underpinned by the prospect of further inflows of funds into the territory.

## South Korean Won and Hong Kong Dollar against US Dollar




*Note: Data are up to 29 September. 2005.*
Source: Federal Reserve Bank of New York

នៅខែកក្កដា២០០៥ ដុល្លារសិង្ហបុរី ធ្លាក់ថ្លៃ (១ដុល្លារUS ប្តូរបាន ១,៦៨១ដុល្លារសិង្ហបុរី ធៀបនឹង ១,៦៦២ដុល្លារសិង្ហបុរីនៅខែមិថុនា) ដោយសារធនាគារ និងវិនិយោគិននៅសិង្ហបុរី បានទិញដុល្លារUS យ៉ាងច្រើនក្រោយដែល ធនាគារកណ្តាលUS បានតំលើងអត្រាការប្រាក់ ។ ក្នុងពេលដដែល ប្រាក់បាតថៃឡើងថ្លៃបន្តិចដល់ ៤១,០៤បាត/ដុល្លារUS រឺឡើងថ្លៃ ០,២% ធៀបនឹងខែមុន ដោយសារមានកំនើនអត្រាការប្រាក់ និងការសំចៃថាមពល

In July 2005, the Singapore dollar slid against the US dollar, depreciating to 1.681 from 1.662 in June. This was mainly due to heavy US dollar buying by Singapore's local banks and investors' betting on further rate increases by the US Federal Reserve. Meanwhile, the Thai baht slightly strengthened against the US dollar, trading at 41.04, a 0.2 percent appreciation from a month earlier. Higher interest rate and energy saving policies were the reasons behind the baht's upward trend.

## Thai Baht and Singaporean Dollar against US Dollar




*Note: Data are up to 29 September 2005.*
Source: Federal Reserve Bank of New York

# ស្ថានភាពតំលៃទំនិញលើទីផ្សារអន្តរជាតិ

# Commodity Prices in World Markets

នៅខែសីហា ថ្លៃអង្ករក្នុងពិភពលោកកើនឡើងដោយសារមិនសូវមានអង្ករសំរាប់នាំចេញ។ សន្ទស្សន៍ថ្លៃអន្តរជាតិ (IPO) កើនបាន ១,៤ ពី ១១៣,១ ដល់ ១១៤,៥ ។ អង្ករនៅ US ចុះថ្លៃដល់ ២៧៦ដុល្លារ/តោន ធៀបនឹង ១៩៦ដុល្លារ/តោននៅខែកក្កដា ដោយសារការប្រមូលផលថ្មីធ្វើឱ្យមានសល់អង្ករច្រើនសំរាប់នាំចេញ ។ នៅថៃ អង្ករឡើងថ្លៃ ៣% ព្រោះមិនសូវមានច្រើន។ ដោយឡែក អង្ករ Thai100%B លក់ថ្លៃ ២៨៦ដុល្លារ/តោន នៅខែសីហា ធៀបនឹង ២៨០ដុល្លារ/តោននៅខែកក្កដា ។

In August, world rice prices rose due to a scarcity of exportable rice. The international prices index (IPO) rose by 1.4 points, from 113.1 points in July to 114.5 points in August. Rice prices in the US went down from US$296 per ton in July to US$276 per ton due to the arrival of the new harvest and a large exportable surplus. In Thailand, prices rose by 3 percent in August because of rice scarcity. The Thai100%B rice was at US$286 per ton in August against US$280 per ton in July.

### International Prices Index and Export Rice Prices

(US$/ton FOB)




Sources: Osiriz/InfoArroz and InterRice

នៅខែកញ្ញា សណ្តែកសៀងឡើងថ្លៃ ប៉ុន្តែពោតចុះថ្លៃ ។ សណ្តែកសៀងលក់បាន ២២៦,៩០ដុល្លារ/តោន ធៀបនឹង ២១៨,២០ដុល្លារ/តោន នៅខែសីហា រីឡើងថ្លៃ ៤% ។ ពោតលក់បាន ៩៦,៨៥ដុល្លារ/តោន នៅខែកញ្ញា ធៀបនឹង ៩៨,៦២ដុល្លារ/តោន នៅខែសីហា រីចុះថ្លៃ ២% ។ ប្រេងឆាចុះថ្លៃ ដល់ ៤០៧ដុល្លារ/តោន នៅខែសីហា ធៀបនឹង ៤១៧ដុល្លារ/តោន នៅខែកក្កដា។

In September, the price of soybeans rose, while the price of maize went down. Soybeans sold at US$226.90 per ton in September, against US$218.20 per ton in August, a 4 percent increase. The price of maize declined by 2 percent, from US$98.62 per ton in August to US$96.85 in September. The price of palm oil fell to US$407 per ton in August from US$417 in July.

### International Prices of Palm Oil and Groundnuts (US$/ton FOB)




Source: Food and Agriculture Organisation

នៅខែកញ្ញា ប្រេងឆៅ និងសាំងបន្តឡើងថ្លៃ ។ ថ្លៃប្រេងឆៅលក់ដល់ដៃរបស់ប្រទេស OPEC គឺ ៥៩,៨៣ដុល្លារ/ធុង នៅខែកញ្ញា រី កំនើន ៣% ធៀបនឹងខែមុន និង កំនើន ៥៧%ធៀបនឹងខែដូចគ្នាឆ្នាំមុន ។ សាំងធម្មតានៅ US Gulf Coast ឡើងថ្លៃដល់ ៦០,៨២សេន/លីត្រ ធៀបនឹង ៥១,០៥សេន/លីត្រនៅខែសីហា រីឡើងថ្លៃ ១៩% ។

In September, the prices of crude oil and gasoline continued to rise. The OPEC countries spot price of crude oil in September was US$59.83 per barrel, a 3 percent increase from the previous month and 57 percent increase from the same month last year. Regular gasoline in the US Gulf Coast in September rose by 19 percent from the previous month, selling at 60.82 cents per litre against 51.05 cents per litre in August.

### Prices of Crude Oil and Gasoline




***Note: Data are up to 30 September** 2005.*

Source: US Energy Information Administration

# ព័ត៌មានសេដ្ឋកិច្ច

# Economic News

**ធនាគារអូស្ត្រាលីចាប់ផ្តើមដំណើរការនៅកម្ពុជា:** ធនាគារ អេអិនហ្សេត របស់អូស្ត្រាលីបានចាប់ផ្តើប្រតិបត្តិការជាផ្លូវការនៅកម្ពុជា ជាមួយសាជីវកម្មក្នុងស្រុក មួយឈ្មោះថា រ៉ូយាល់គ្រុប។ ធនាគារ អេអិនហ្សេត រ៉ូយាល់ គឺជាធនាគារទីមួយនៅកម្ពុជាដែលមានភាគហ៊ុនភាគច្រើនមកពីប្រទេសមិនមែនអាស៊ីអាគ្នេយ៍ ។ សាខាចំនួនបួនបានបង្កើតរួចហើយ នៅភ្នំពេញ និងមានសាខាជាច្រើនទៀតគ្រោងនឹងបង្កើតឡើងនៅខេត្តសៀមរាប និង បាត់ដំបង នាដើមឆ្នាំក្រោយ ។ រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ គង់ វិបុល មានប្រសាសន៍ថា វត្តមានធនាគារនេះបង្ហាញពីលទ្ធផលនៃកិច្ចប្រឹងប្រែងរបស់រដ្ឋាភិបាលក្នុងការពង្រឹងច្បាប់ធនាគារ ហើយគេសង្ឃឹមថាវាជាការចាប់ផ្តើមសម័យថ្មីមួយនៃប្រតិបត្តិការធនាគារពាណិជ្ជកម្មនៅកម្ពុជា ហើយនឹងទាក់ទាញឱ្យមានធនាគារអន្តជាតិជាច្រើនចូលមកទៀត។ នៅក្នុងកិច្ចព្រមព្រៀងកាលពីខែវិច្ឆិកា អេអិនហ្សិត មានភាគហ៊ុន ៥៥% នៅក្នុងធនាគារថ្មីនេះ ហើយភាគហ៊ុនដែលនៅសល់ជារបស់ ក្រុមហ៊ុន រ៉ូយាល់គ្រុប ។

**អាឡឺម៉ង់ជួយកម្ពុជាក្នុងការអភិវឌ្ឍន៍ប្រព័ន្ធអគ្គីសនី:** រដ្ឋាភិបាល អាឡឺម៉ង់ បានសន្យាផ្តល់ជំនួយ ១៥លានដុល្លារ សំរាប់ឱ្យកម្ពុជារៀបចំបណ្តាញអគ្គីសនីពីខេត្តតាកែវ ទៅកំពត ។ កិច្ចព្រមព្រៀងបានចុះហត្ថលេខានៅភ្នំពេញ ដោយតំណាងរបស់ស្ថានទូតអាឡឺម៉ង់ និង រដ្ឋាភិបាលកម្ពុជា។ គំរោងមានគោលដៅធានាឱ្យអគ្គីសនីមានថ្លៃសមរម្យ និងជួយសំរួលដល់ការអភិវឌ្ឍន៍សេដ្ឋកិច្ច-សង្គមកិច្ចនៅក្នុងតំបន់ ។ គំរោងនេះបានទទួលមូលនិធិពីធនាគារពិភពលោក និងធនាគារអភិវឌ្ឍន៍អាស៊ី ហើយនិងជួយបង្កើនសមត្ថភាពបណ្តាញអគ្គីសនីជាតិ ដល់ ២៣០kW ព្រមទាំងជួយដល់ការនាំចូលអគ្គីសនីពីវៀតណាម ។

**មន្ត្រីអាស៊ាន+៣ ពិភាក្សាពីកម្មវិធីសហប្រតិបត្តិការ, កិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីនៅអាស៊ីខាងកើត:** មន្ត្រីសេដ្ឋកិច្ចថ្នាក់ខ្ពស់មកពីប្រទេសអាស៊ានទាំង ១០ និងដៃគូសំខាន់ៗ (ចិន ជប៉ុន និង កូរ៉េខាង ត្បូង) ផ្តោតការពិភាក្សាទៅលើកិច្ចសហប្រតិបត្តិការដ៏ជាក់លាក់ ដើម្បីជំរុញសហប្រតិបត្តិការសេដ្ឋកិច្ចរបស់អាស៊ាន+៣ និងលទ្ធភាពបង្កើតប្រព័ន្ធគ្រប់គ្រងមហន្តរាយក្នុងតំបន់ និងកម្មវិធីបណ្តុះបណ្តាលជំនាញគ្រប់គ្រងគំរោងវិស្វកម្មអន្តរជាតិសំរាប់សមាជិកអាស៊ាន ។ អ្នកតំណាងនានាក៏បានពិភាក្សាពីលទ្ធភាពបង្កើតតំបន់ពាណិជ្ជកម្មសេរីអាស៊ីខាងកើត ដែលនាយករដ្ឋមន្ត្រីចិន វិន ជីប៉ាវ បានលើកឡើងនៅឆ្នាំ២០០៣។ គេបានកត់សំគាល់ថាក្នុងប៉ុន្មានឆ្នាំថ្មីៗ ប្រទេសអាស៊ាន+៣ មានកិច្ចសហប្រតិបត្តិការជិតស្និទ្ធជាងមុនខាងសេដ្ឋកិច្ច រូបិយវត្ថុ ហិរញ្ញវត្ថុ ។ ពាណិជ្ជកម្មសរុបរបស់ពួកគេកើនប្រហែល ១៤,៥% ដល់ ១៩៥,៦ ពាន់លានដុល្លារនៅឆ្នាំ ២០០៣ ។

**ការពិភាក្សាពាណិជ្ជកម្មរវាងអាស៊ាន និង ៧ប្រទេស:** មន្ត្រីជាន់ខ្ពស់អាស៊ាន បានបញ្ចប់ការពិភាក្សាមួយខ្សែជាមួយ ៧ប្រទេសដៃគូ រួមមានចិន ជប៉ុន កូរ៉េខាងត្បូង សហរដ្ឋអាមេរិក នូវែលហ្សឺឡង់ និង អូស្ត្រាលី ដើម្បីបង្កើតកិច្ចព្រមព្រៀងពាណិជ្ជកម្ម និងជំរុញទំនាក់ទំនងសេដ្ឋកិច្ចទ្វេភាគី ។

***Australian bank launches in Cambodia:*** Australia's ANZ bank has formally launched operations in Cambodia with a local conglomerate, the Royal Group. ANZ Royal Bank is the first non-southeast-Asian majority-owned bank in Cambodia. Four branches have opened in Phnom Penh, with branches planned in Siem Reap and Battambang by early next year. Ministry of Economy and Finance Secretary of State Kong Vibol says the bank's presence shows government efforts to strengthen banking laws are working. He says it is hoped this will be the dawn of a new era in commercial banking in Cambodia and will trigger the entry of more international banks. Under a deal signed last November, ANZ took a 55 percent stake in the new bank, while Royal Group holds the remainder. *(From abc.net.au, 16 September 2005)*

***Germany helps Cambodia develop electricity system:*** The German government has pledged $15 million in aid to help Cambodia install an electricity grid from Takeo to Kampot provinces. An agreement to this effect was signed in Phnom Penh last week between representatives of the German embassy and the Cambodian government. The project aims to ensure that electricity is reasonably priced and will facilitate socio-economic development in the areas. The project, which is jointly funded by the World Bank and the Asian Development Bank, will help increase the national electricity network's capacity to 230 kW and will also help import power from Viet Nam. *(From VNA, 15 September 2005).*

***ASEAN+3 economic officials discuss cooperation programmes, east Asia FTA:*** Senior economic officials from the 10-member ASEAN and its dialogue partners, China, Japan and South Korea, centred their discussions on specific cooperation in enhancing ASEAN+3 economic cooperation, and the possibility of establishing a regional disaster management system and an international engineering project management training programme for members of ASEAN. The consultation's delegates also probed into the possible establishment of an east Asia free trade area, which was proposed by Chinese Premier Wen Jiabao in 2003. It is noted that the ASEAN+3 countries have seen closer cooperation on economic, monetary and financial fields in recent years. Their total trade rose by roughly 14.5 percent to $195.6 billion 2003. *(From Xinhua News Agency, 25 September 2005)*

***ASEAN talks trade with seven countries:*** Senior ASEAN officials last week wrapped up a series of talks in Bangkok with seven partners, including China, Japan, South Korea, the United States, New Zealand and Australia, in a bid to create trade deals and enhance bilateral economic relations. *(From the Nation, 1 September 2005*